# ការរក្សាការពារក្នុងរឿងក្ដីរដ្ឋប្បវេណី

# ផ្នែក 5

# ការអនុវត្តការរក្សាការពារ

# សេចក្ដីពន្យល់បន្ថែម

ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៨

ជំនាញការនៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់
MAEDA Yuta

- Slide 3

ដោយសារតែការអនុវត្តនូវការរក្សាការពារចាំបាច់ឲ្យមានភាពឆាប់រហ័ស ហេតុនេះមិនចាំបាច់មាននូវរូបមន្តអនុវត្តទេ។ ប៉ុន្តែ ក្នុងករណីមានការផ្លាស់ប្តូរភាគីដោយសារមរណភាពរបស់ភាគីជាអាទិ៍ នោះតុលាការចាំបាច់ត្រូវត្រួតពិនិត្យនូវទំនាក់ទំនងនៃការទទួលបន្ត ដូច្នេះចាំបាច់ត្រូវមាននូវរូបមន្តអនុវត្តពិសេស។

មិនចាំបាច់បញ្ចប់ការអនុវត្តក្នុងរយៈពេលពីរសប្តាហ៍ទេ ត្រឹមតែចាប់ផ្តើមការអនុវត្តគឺគ្រប់គ្រាន់។ តើអ្វីទៅគឺជាការចាប់ផ្តើម វាគឺមានភាពខុសគ្នាតាមប្រភេទនៃដីកាសម្រេចរក្សាការពារនីមួយៗ។ ឧទាហរណ៍ថា ចំពោះការអនុវត្តនូវដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលើអចលនវត្ថុ ចំណុចនៃការចាប់ផ្តើមអនុវត្ត គឺអាចនិយាយបានថា នៅពេលដែលតុលាការបង្គាប់ឲ្យផ្ទុកផ្តាក់ឲ្យការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន។

ចំពោះការអនុវត្តការចាត់ចែងជាបណ្តោះអាសន្នដែលបង្គាប់មិនឲ្យធ្វើសកម្មភាព ជាធម្មតានឹងត្រូវបានធ្វើឡើងដោយប្រើវិធីនៃវិធានបង្ខំដោយប្រយោល ហើយបើសិនជាកូនបំណុលមិនធ្វើអ្វីសោះតាំងពីដំបូង នោះក៏មិនមានភាពចាំបាច់ក្នុងការអនុវត្តដែរ ម្យ៉ាងទៀត ប្រសិនបើពិចារណាអំពីរយៈពេលច្រើនដែលត្រូវប្រើដើម្បីឲ្យម្ចាស់បំណុលអាចដឹងអំពីសកម្មភាពផ្ទុយដែលកូនបំណុលបានធ្វើផ្ទុយនឹងដីកាសម្រេចជាអាទិ៍ នៅប្រទេសជប៉ុនមានគំនិតដែលលើកឡើងថា ពុំមានការអនុវត្តអំពីការកម្រិតអំឡុងពេលចំពោះការអនុវត្តការចាត់ចែងជាបណ្តោះអាសន្នដែលបង្គាប់មិនឲ្យធ្វើសកម្មភាពទេ ហេតុនេះ នៅប្រទេសជប៉ុនអំឡុងពេលនោះនឹងមានសុពលភាព។

ប្រសិនបើបញ្ជូនដីកាសម្រេចរក្សាការពារទៅឲ្យកូនបំណុលនៅមុនពេលអនុវត្ត នោះនឹងត្រូវចំណាយពេលវេលាច្រើន ហើយនឹងមានការព្រួយបារម្ភថា កូនបំណុលដែលបានដឹងអំពីដីកាសម្រេចរក្សាការពារនឹងដកប្រាក់បញ្ញើដែលជាកម្មវត្ថុ។ ដោយផ្អែកលើការលើកឡើងទាំងនេះ ដើម្បីរក្សាការពារនូវភាពបន្ទាន់ ភាពជាសម្ងាត់ ទើបគេបកស្រាយថា ទោះបីជានៅមុនពេលដែលដីកាសម្រេចរក្សាការពារបញ្ជូនទៅដល់កូនបំណុលក៏ដោយ ក៏អាចអនុវត្តបានដែរ។

- Slide 4

ទោះបីជាដីកាសម្រេចរក្សាការពារត្រូវបានធ្វើឧបាស្រ័យក៏ដោយ ក៏ការធ្វើឧបាស្រ័យមិនមានអានុភាពផ្អាកការអនុវត្តដែរ ហេតុនេះ នៅប្រទេសជប៉ុនមានគំនិតលើកឡើងថា ការធ្វើឧបាស្រ័យពុំអាចផ្អាកនូវការបន្តអំឡុងពេលអនុវត្តទេ ហេតុនេះ អំឡុងពេលអនុវត្តគឺមានសុពលភាព។ ដូចនេះ ក្នុងករណីដែលតុលាការបានចេញដីកាសម្រេចទទួលស្គាល់នូវ ដីកាសម្រេចរក្សាការពារចំពោះការតវ៉ាការរក្សាការពារ ឬ ករណីដែលបណ្តឹងជំទាស់ចំពោះដីកាសម្រេចនោះត្រូវបានលើកចោលក៏ដោយ ក៏អំឡុងពេលអនុវត្តថ្មីមិនបន្តដែរ។ យ៉ាងណាមិញ ក្នុងករណីដែលតុលាការចេញដីកាសម្រេចផ្អាកការអនុវត្តអំឡុងពេលអនុវត្តដែលត្រូវបន្តនឹងផ្អាក ហើយអំឡុងពេលអនុវត្ត២សប្តាហ៍ថ្មីនឹងត្រូវបន្ត គិតចាប់ពីថ្ងៃ

ដែលដីកាសម្រេចលុបចោលការផ្អាកការអនុវត្តត្រូវបានបញ្ជូនទៅម្ចាស់បំណុលនៅពេលបន្ទាប់។

- Slide 7

ម្ចាស់បំណុលត្រូវតែសរសេរអំពីទីតាំងដែលចលនវត្ថុត្រូវរឹបអូសស្ថិតនៅ ចូលទៅក្នុងលិខិតពាក្យសុំការអនុវត្ត (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៥៦៥ កថា.ទី៤ មាត្រា៣៨៤ កថា.ទី២) ហើយអាជ្ញាសាលានឹងជ្រើសរើសកម្មវត្ថុនៅទីកន្លែងនោះ។

- Slide 8

ការរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុ ជាការរឹបអូសដែលធ្វើឡើងក្នុងគោលបំណងរក្សាការពារនូវការអនុវត្តលើចលនវត្ថុនាពេលអនាគត ហេតុនេះ ចំពោះចលនវត្ថុដែលត្រូវបានហាមឃាត់មិនឲ្យរឹបអូសយោងតាមក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា៣៨០ មិនអាចធ្វើការអនុវត្តរឹបអូសជាបណ្តោះអាសន្នបានទេ។

- Slide 9

វិធីនៃការរឹបអូសជាបណ្តោះអាសន្នចំពោះនាវាមានពីរ ហើយវិធីទាំងនោះអាចអនុវត្តរួមគ្នាបាន (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៥៦៨ កថា.ទី១)។

- Slide 11

ក្នុងករណីដែលតុលាការមិនអនុញ្ញាតឲ្យកូនបំណុលប្រើប្រាស់កម្មវត្ថុ អាជ្ញាសាលាត្រូវដកហូតកម្មវត្ថុនោះពីកូនបំណុលដោយផ្ទាល់ ហើយចាំបាច់តែត្រូវថែរក្សាគ្រប់គ្រងដោយខ្លួនឯង ឬ ប្រគល់កម្មវត្ថុឲ្យទៅអ្នកថែរក្សាគ្រប់គ្រង។

បញ្ញត្តិដែលស្តីពី ការដាក់ពាក្យសុំត្រូវធ្វើទៅកាន់អាជ្ញាសាលាមួយណា នឹងត្រូវកំណត់នៅក្នុងច្បាប់ស្តីពីអាជ្ញាសាលា។

- Slide 12

ការអនុវត្តនូវការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែងចំពោះអចលនវត្ថុ នឹងត្រូវធ្វើឡើងដូចគ្នាទៅនឹងការអនុវត្តនូវការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ។ ដូចនេះ វាដូចគ្នាទៅនឹងការអនុវត្តនូវការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ហេតុនេះ នឹងត្រូវធ្វើការចុះបញ្ជីអំពីការចាត់ចែងជាបណ្តោះអាសន្ន ហើយតុលាការដែលមានសមត្ថកិច្ច គឺ តុលាការដែលបានចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ហើយអានុភាពនៃការអនុវត្តនឹងកើតមាននៅក្រោយពេលនៃការចុះបញ្ជី។

- Slide 13

ឧទាហរណ៍ ចំពោះការចាត់ចែងជាបណ្តោះអាសន្នដែលបង្គាប់ឲ្យរុះរើរបង នឹងធ្វើការអនុវត្តតាម

វិធីនៃការអនុវត្តជំនួស។ ម្យ៉ាងវិញទៀត ចំពោះការចាត់ចែងជាបណ្តោះអាសន្នដែលបង្គាប់មិនឲ្យធ្វើសកម្មភាព នឹងធ្វើការអនុវត្តដោយប្រើវិធានបង្ខំដោយប្រយោល ឬ ការអនុវត្តជំនួសលើវត្ថុដែលបានកើតឡើងដែលផ្ទុយទៅនឹងការបង្គាប់មិនឲ្យធ្វើសកម្មភាព។

សូមអរគុណ